# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**និយ័តករគណនេយ្យនិងសវនកម្ម**

លេខ.......✓.............ន. គ. ស .......

ថ្ងៃព្រហ.៨កើតខែអាសាឍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ, ថ្ងៃទី៣ ខែកក្កដា គ.ស.២០២៥

# សេចក្តីជូនដំណឹង
## ស្តីពី
## ការពន្យារពេលវេលាបន្ថែមក្នុងការទទួលលិខិតស្នើសុំពន្យារពេលសម្រាប់បញ្ចប់ការងារសវនកម្មឯករាជ្យ និងបោះផ្សាយមតិសវនកម្មឯករាជ្យ សម្រាប់ការិយបរិច្ឆេទគណនេយ្យ២០២៤ មកនិយ័តករគណនេយ្យនិងសវនកម្ម

និយ័តករគណនេយ្យនិងសវនកម្ម (**ន.គ.ស.**) នៃ អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) សូមជម្រាបជូន លោក លោកស្រី ជាម្ចាស់សហគ្រាស និងប្រធានអង្គភាពមិនស្វែងរកប្រាក់ចំណេញ(អង្គភាព) រងសវនកម្មឯករាជ្យជ្រាបថា៖ យោងតាមសេចក្តីជូនដំណឹងចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២៥ ស្តីពីការរំលឹកកាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យ និងការដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុរងសវនកម្មឯករាជ្យប្រចាំឆ្នាំ២០២៤ មកនិយ័តករគណនេយ្យនិងសវនកម្ម កាលបរិច្ឆេទនៃការបញ្ចប់ការងារសវនកម្មឯករាជ្យ និងបោះផ្សាយមតិសវនកម្មឯករាជ្យ *ត្រូវបានផុតកំណត់ត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៥*។ ជាក់ស្តែងរហូតមកដល់ពេលនេះ នៅមានសហគ្រាសនិងអង្គភាពមួយចំនួនមានភាពយឺតយ៉ាវក្នុងការដាក់ពាក្យស្នើសុំពន្យារពេលបញ្ចប់ការងារសវនកម្មឯករាជ្យ និងបោះផ្សាយមតិសវនកម្មឯករាជ្យ មក **ន.គ.ស.** តាមកាលកំណត់ខាងលើនេះ។

ដើម្បីផ្តល់ភាពទន់ភ្លន់ **ន.គ.ស.** សម្រេចផ្តល់ពេលវេលា ចំនួន២០(ម្ភៃ) ថ្ងៃបន្ថែមទៀតសម្រាប់សហគ្រាស និងអង្គភាពរងសវនកម្មឯករាជ្យក្នុងការដាក់លិខិតស្នើសុំពន្យារពេលសម្រាប់បញ្ចប់ការងារសវនកម្មឯករាជ្យ និងបោះផ្សាយមតិសវនកម្មឯករាជ្យ សម្រាប់ការិយបរិច្ឆេទគណនេយ្យ២០២៤ ដោយសហគ្រាស និងអង្គភាព ត្រូវដាក់លិខិតស្នើសុំពន្យារពេលសម្រាប់ការបញ្ចប់ការងារសវនកម្មឯករាជ្យ និងបោះផ្សាយមតិសវនកម្មឯករាជ្យមក **ន.គ.ស.**មិនឱ្យហួស *ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២៥*។

បញ្ជាក់៖សហគ្រាស និងអង្គភាពត្រូវបង់កម្រៃសេវាតាមប្រកាសលេខ០០២ អ.ស.ហ. ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០២៥ ស្តីពីសេវាសាធារណៈរបស់និយ័តករគណនេយ្យនិងសវនកម្មជាធរមាន។

សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទងមន្ត្រី **ន.គ.ស.** តាមរយៈលេខទូរស័ព្ទ និងតេឡេក្រាមដូចខាងក្រោម៖

- សម្រាប់សហគ្រាស ៖ ០៨៦ ៩ ១៩៩ ៩៩៨/ ០៧៧ ៨០៥ ៥៥២/ ០១០ ៦៩៤ ៦២២/ ០១៦ ៥៩៨ ៣៨៦។
- សម្រាប់អង្គភាព ៖ ០៨១ ៦៤៤ ៦៦៣/ ០៩២ ៦៨៨ ២៩៧/ ០៨៥ ៩០៤ ៨៤៨/ ០៨៥ ៤៤៤ ៤៨៨។

*ការខកខានមិនបានដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុរងសវនកម្មឯករាជ្យប្រចាំឆ្នាំ២០២៤ មក ន.គ.ស ជាកម្មវត្ថុនៃការអនុវត្តវិធានការតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។*

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមម្ចាស់សហគ្រាស និងប្រធានអង្គភាពរងសវនកម្មឯករាជ្យ ជ្រាបជាព័ត៌មាន និងចូលរួមអនុវត្តខ្លឹមសារនៃសេចក្តីជូនដំណឹងនេះឱ្យមានប្រសិទ្ធភាពខ្ពស់។

**និយ័តករគណនេយ្យនិងសវនកម្ម**

ដើម្បីទទួលបាន ឬសាកសួរព័ត៌មាន
អំពីវិស័យនិងវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម
សូមចូលរួមក្នុង Telegram Channel របស់ ន.គ.ស